# គម្រោងពង្រឹងសមត្ថភាពផលិតភាពជនបទដំហ៊ាន ២

សេចក្តីសង្ខេបស្តីពីក្របខ័ណ្ឌផែនការដោះស្រាយផលប៉ះពាល់ដោយមិនស្ម័គ្រចិត្ត

## អំពីគម្រោង

រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា (GKC) បានទទួលហិរញ្ញប្បទានពីធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី (AIIB) ដើម្បីជួយផ្តល់ហិរញ្ញប្បទានដល់គម្រោង ពង្រឹងសមត្ថភាពផលិតភាពជនបទដំហ៊ាន ២ ឬ NRRPCP-2 ដែលត្រូវបានគេកំណត់ថាជាអាទិភាពក្នុងការពង្រឹងការតភ្ជាប់ទីជនបទរបស់រដ្ឋាភិបាល។ គោលបំណងនៃគម្រោងនឹងសម្រេចបានតាមរយៈការរក្សា និងពន្លឿនការចំណាយលើហេដ្ឋារចនាសម្ព័ន្ធជនបទ បង្កើតការងាររយៈពេលខ្លី និងបង្កើតប្រាក់ចំណូល កសាងសមត្ថភាពការងារក្នុងស្រុក និងអ្នកម៉ៅការថ្នាក់ជាតិ ដើម្បីធានាបាននូវការកសាងហេដ្ឋារចនាសម្ព័ន្ធជនបទប្រកបដោយគុណភាពតាមស្តង់ដារជាតិដែលបានបង្កើតឡើងជាមួយដៃគូអភិវឌ្ឍន៍ និងបង្កើតមូលដ្ឋានគ្រឹះសម្រាប់ ការរៀនសូត្រ និងការចែករំលែកចំណេះដឹងក្នុងចំណោមភាគីពាក់ព័ន្ធសំខាន់ៗនៃគម្រោង ដើម្បីពង្រីកហេដ្ឋារចនាសម្ព័ន្ធជនបទ និងការផ្តល់សេវាជនបទ។

គម្រោងនេះនឹងផ្តល់ហិរញ្ញប្បទានដល់ការសាងសង់ផ្លូវជនបទយ៉ាងហោចណាស់ ៤១២ គីឡូម៉ែត្រដែលស្ថិតនៅក្នុងខេត្តចំនួន ១០ គឺកំពង់ធ្នាំង ត្បូងឃ្មុំ ព្រៃវែង បាត់ដំបង កំពង់ធំ តាកែវ កណ្តាល ស្វាយរៀង កំពត និងកែប ។ ផ្លូវដែលនឹងត្រូវបានស្តារឡើងវិញទាំងនេះត្រូវបានរំពឹងថា នឹងធ្វើឲ្យប្រសើរឡើងនូវការធ្វើដំណើរពេញមួយឆ្នាំសម្រាប់ប្រជាជននៅទីជនបទ ។ ហេដ្ឋារចនាសម្ព័ន្ធដែលនឹងកែលម្អនេះ នឹងជួយដល់ការធ្វើដំណើរ ការដឹកជញ្ជូនផលិតផលកសិកម្ម និងការតភ្ជាប់ទៅកាន់មណ្ឌលសុខភាព ទីផ្សារ និងសាលារៀន ។ វាត្រូវបានព្យាករណ៍ថាមានប្រជាជននៅជនបទប្រមាណ ១,០០០,០០០ នាក់ នឹងទទួលបានអត្ថប្រយោជន៍ផ្ទាល់ពីគម្រោងរួមទាំងក្រុមងាយរងគ្រោះ ដូចជាស្ត្រី កុមារ យុវជនគ្មានការងារធ្វើ ជនចាស់ជរា ជនមានពិការភាព ពលករចំណាកស្រុកដែលត្រឡប់មក

វិញ និងសហគមន៍ជនជាតិដើមភាគតិច ។ លើសពីនេះ គម្រោងនេះត្រូវបានរំពឹងថានឹងបង្កើតការងាររយៈពេលខ្លីប្រមាណ ៥០,០០០ កន្លែង និងគាំទ្រដល់ការចូលរួមរបស់ក្រុមហ៊ុនម៉ៅការសាងសង់ក្នុងស្រុក ដើម្បីពង្រឹងសមត្ថភាពក្នុងស្រុក ។

1. សេចក្តីសង្ខេបនេះបានលើកយកចំណុចសំខាន់ត្រូវរៀបចំក្របខ័ណ្ឌដោះស្រាយផលប៉ះពាល់ និងផែនការពិស្តារត្រូវបានពិពណ៌នានៅក្នុងអត្ថបទនិងឧបសម្ព័ន្ធនៃក្របខ័ណ្ឌដោះស្រាយផលប៉ះពាល់ដោយមិនស្ម័គ្រចិត្ត
2. ក្របខ័ណ្ឌដោះស្រាយផលប៉ះពាល់នេះត្រូវបានរៀបចំដោយក្រសួងអភិវឌ្ឍន៍ជនបទ សម្រាប់សមាសភាពនៃគម្រោងពង្រឹងសមត្ថភាពផលិតភាពជនបទជំហ៊ានទី២ (NRRPCP-II) ដោយមានការគាំទ្រពីទីប្រឹក្សាបច្ចេក ទេសជាតិ និងអន្តរជាតិ អនុលោមតាមគោលការណ៍អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយគម្រោងអភិវឌ្ឍន៍ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក្របខ័ណ្ឌនេះ ជាផ្នែកមួយនៃក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម ដែលនឹងត្រូវយកមកប្រើប្រាស់ចំពោះគម្រោងវិនិយោគ ក្រោមហិរញ្ញប្បទានរបស់ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី សំដៅផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ដល់គម្រោងពង្រឹងសមត្ថភាពផលិតភាពជនបទ នៅកម្ពុជាក្នុងការដោះស្រាយផលប៉ះពាល់។ ឯកសារនេះ ត្រូវបានរៀបចំស្របតាមស្តង់ដានៃនីតិវិធី ប្រតិបត្តិការដោះស្រាយផលប៉ះពាល់របស់រាជរដ្ឋាភិបាលកម្ពុជា និងមានសង្គតិភាពជាមួយឯកសារក្របខ័ណ្ឌបរិស្ថាន និងសង្គមរបស់ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី
3. ដំណើការអនុវត្តគម្រោងរំពឹងថានឹងមិនមានផលប៉ះពាល់ដល់បញ្ហាដីធ្លី ឬទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋលើការកែលម្អផ្លូវជនបទឡើយ ក្នុងករណីបើមានផលប៉ះពាល់ហើយមិនមានការផ្តល់ ឬបរិច្ចាគដោយស្ម័គ្រចិត្តពីប្រជាពលរដ្ឋទេ នោះគោលការណ៍ដោះស្រាយផលប៉ះពាល់ត្រូវបានអនុវត្ត។
4. ព្រះរាជាណាចក្រកម្ពុជា ច្បាប់អស្សាមិករណ៍ (២០១០) គឺជាឯកសារច្បាប់ដ៏សំខាន់មួយដែលផ្តោតលើការដោះស្រាយផលប៉ះពាល់។ មាត្រាទី៣៖ គម្រោងហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ រាជរដ្ឋាភិបាល កម្ពុជាបានចេញនូវស្តង់ដានីតិវិធីប្រតិបត្តិ (SOP) នៅឆ្នាំ២០១៨ ដាក់ឲ្យប្រើប្រាស់សម្រាប់ ជាយន្តការក្នុងការដោះស្រាយផលប៉ះពាល់។ អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយគម្រោងអភិវឌ្ឍន៍ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទទួលខុសត្រូវក្នុងការផ្តល់គោលការណ៍ណែនាំដល់អ្នកប្រើប្រើប្រាស់ឯកសារ SOP ដោយគម្រោងពង្រឹងសមត្ថភាពផលិតភាពជនបទ ផ្តល់ហិរញ្ញប្បទានដោយធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ីត្រូវអនុវត្តតាមខ្លឹមសារនៃការណែនាំដូចមានចែងក្នុងSOP។ ឯកសារក្របខ័ណ្ឌដោះស្រាយផលប៉ះពាល់ រៀបចំឡើងដោយអនុលោមតាមស្តង់ដាទី២ ស្តីពីបរិស្ថាន និងសង្គមរបស់ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី

លើការ ដោះស្រាយផលប៉ះពាល់ពេលអនុវត្តគម្រោង។ មានចំណុចខ្វះចន្លោះតិចតួច រវាងស្តង់ដានីតិវិធីប្រតិបត្តិ និងស្តង់ដាទី២ របស់ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី ត្រង់ថាមិនមានការបរិយាយអំពីគោលការណ៍ក្នុងការ ស្ម័គ្រចិត្តបរិច្ចាគពីសំណាក់អ្នកពាក់ព័ន្ធ ឬអ្នកទទួលរងផលប៉ះពាល់ គឺមានតែគោលការណ៍ចំពោះ អ្នកដែលមិនស្ម័គ្រចិត្តបរិច្ចាគ ត្រូវដោះស្រាយផលប៉ះពាល់ ដូចនេះឯកសារក្របខ័ណ្ឌដោះស្រាយផលប៉ះពាល់នឹងការរៀបរាប់អំពីដំណើការ និងនីតិវិធីសម្រាប់ការស្ម័គ្រចិត្តបរិច្ចាគនិងមានសង្គតិភាពជាមួយស្តង់ដារបស់ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី។

5. គម្រោងមាននីតិវិធីគ្រប់គ្រងការដោះស្រាយផលប៉ះពាល់ដោយអនុលោមតាមឋានានុក្រមក្នុងការកាត់បន្ថយផលប៉ះពាល់ និងហានិភ័យ ដូចខាងក្រោម៖
   - កែសម្រួលគ្រោងប្លង់ដើម្បីបញ្ចៀសផលប៉ះពាល់លើដី និងទ្រព្យសម្បត្តិ
   - បើសិនជាមិនអាចជៀសបាន បង្រួមផលប៉ះពាល់អោយនៅកម្រិតអប្បរមា
   - ពិគ្រោះយោបល់ជាមួយពលរដ្ឋដែលរងផលប៉ះពាល់ ដើម្បីផ្តល់ជម្រើស និងលើកទឹកចិត្តដល់ពួកគាត់ធ្វើការបរិច្ចាគដោយស្ម័គ្រចិត្ត ជៀសជាងការផ្តល់សំណង ករណីជាលក្ខណៈវិនិច្ឆ័យដែលរៀបរាប់នៅក្នុងក្របខ័ណ្ឌដោះស្រាយផលប៉ះពាល់ត្រូវបានអនុវត្ត
   - ចំពោះអ្នកមិនព្រមបរិច្ចាគដោយស្ម័គ្រចិត្ត ឬមិនសមស្របនឹងលក្ខណៈវិនិច្ឆ័យ (i) ផ្តល់សំណងទៅតាមតម្លៃជំនួសនៃការផ្លាស់ប្តូរទីតាំងដី-ទ្រព្យដែលបាត់បង់ ឬប្តូរដីជំនួសសម្រាប់ដីដែល បានបាត់បង់ (ii) ការផ្តល់សំណង នឹងត្រូវធ្វើឡើងមុនពេលចាប់ផ្តើមការងារសាងសង់ ហើយផែនការដោះស្រាយផលប៉ះពាល់ត្រូវបានផ្សព្វផ្សាយដើម្បីជូនដំណឹងជាសាធារណៈអំពីដំណើរការនៃការដោះស្រាយបណ្តឹងតវ៉ា

6. ឯកសារនេះមានវិសាលភាពគ្របដណ្តប់លើ (i) ដី/ទ្រព្យដែលបរិច្ចាគដោយស្ម័គ្រចិត្ត (i) ដី/ទ្រព្យដែលបរិច្ចាគដោយមិនស្ម័គ្រចិត្ត។ ការបរិច្ចាគដោយស្ម័គ្រចិត្ត ត្រូវធ្វើឡើងដោយមានការជូនដំណឹង និងពន្យល់ច្បាស់លាស់ ព្រមទាំងរៀបចំចងក្រងជាឯកសារត្រឹមត្រូវ ដោយប្រជាពលរដ្ឋត្រូវបានជ្រាបថាពួកគាត់ដែលកំពុងរស់នៅតាមខ្សែផ្លូវគម្រោង នឹងត្រូវទទួលបានអត្ថប្រយោជន៍ដោយផ្ទាល់ ធំធេងពីគម្រោង បើប្រៀបធៀបនឹងការបរិច្ចាគបន្តិចបន្តួចដូចជា ផ្លូវចូលផ្ទះ ឬរបងផ្ទះរបស់ពួកគាត់។ ករណីការបរិច្ចាគដោយមិនស្ម័គ្រចិត្ត នឹងមានការរៀបចំពិស្តារនូវរចនាសម្ព័ន្ធស្ថាប័នទទួលខុសត្រូវ និងតួនាទីភារកិច្ច ការពិគ្រោះយោបល់ ការផ្សព្វផ្សាយអំពីគម្រោង និងយន្តការផ្តល់សំណង ព្រមទាំងការត្រួតពិនិត្យវាយតម្លៃ ។

7. ក្របខ័ណ្ឌដោះស្រាយផលប៉ះពាល់ ត្រូវអនុវត្តចំពោះការផ្លាស់ប្តូរទីលំនៅបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍ដូចមានចែងក្នុងឯកសារស្តង់នីតិវិធីប្រតិបត្តិរបស់រាជរដ្ឋាភិបាលកម្ពុជា និងគោលការណ៍របស់ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី។ គ្រួសារដែលរងផលប៉ះពាល់ ដែលមានដី/ទ្រព្យនៅលើខ្សែផ្លូវឬស្រះទឹកសហគមន៍ ត្រូវកែលម្អមុនពេលនៃកាលបរិច្ឆេទឌីសានវាទ (Cut-off

date) គឺមានសិទ្ធិអាចទទួលយកសំណងបាន បើសិនពួកគាត់មានលក្ខណៈគ្រប់គ្រាន់ខាងទិដ្ឋភាពច្បាប់ដែលអាចទទួលយកសំណងបានលុះត្រាតែ បញ្ហារបស់ពួកគាត់ត្រូវបានលើកមកពិភាក្សានៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់លើកទី១ នៅពេល ដែលខ្សែផ្លូវ និងកន្លែងដែលត្រូវបានប៉ះពាល់បានកំណត់ដោយគម្រោង តាមរយៈការផ្សព្វផ្សាយនៅ តាមសាលាឃុំ/សង្កាត់ ផ្ទាំងព័ត៌មានសាធារណៈ ឬតាមវត្តអារាមជាដើម។ ករណីបើមានអ្នកទន្ទ្រាន ឬកាន់កាប់ទីតាំងដី/ទ្រព្យដែលឯកភាជាមួយគម្រោងក្រោយកាលបរិច្ឆេទ នៃកិច្ចប្រជុំពិគ្រោះយោបល់នឹងមិនមានសិទ្ធិទទួលបានសំណង ឬជំនួយផ្សេងៗឡើយ

8. ក្របខណ្ឌដោះស្រាយផលប៉ះពាល់ បានបញ្ជាក់អំពីយន្តការដោះស្រាយបណ្តឹងតវ៉ា ដែលត្រូវបានរៀបចំឡើងនៅតាមតំបន់ ដោយប្រើប្រាស់រចនាសម្ព័ន្ធមានស្រាប់ ក្នុងគោលបំណងដើម្បីទទួលព័ត៌មានត្រឡប់ កត់ត្រា វាយតម្លៃ និងសម្របសម្រួលដោះស្រាយការតវ៉ានានាដែលអាចកើតមានឡើង ពីសំណាក់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ លើដំណើរការនៃការអនុវត្តគម្រោងពង្រឹងសមត្ថភាពផលិតភាពជនបទ ឯកសារក្របខ័ណ្ឌនេះបានរៀបរាប់អំពីនីតិវិធី និងដំណើការក្នុងការពិគ្រោះយោបល់ និងផ្សព្វផ្សាយព័ត៌មាន ក្នុងករណីមានការបរិច្ចាគដោយស្ម័គ្រចិត្ត ហើយឯកសារស្តីពីក្របខ័ណ្ឌដោះស្រាយផលប៉ះពាល់នេះត្រូវបានប្រជុំពិគ្រោះយោបល់នៅថ្នាក់ជាតិជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងត្រូវបានផ្សព្វផ្សាយជាសាធារណៈមុនការវាយតម្លៃគម្រោង។